ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង

លេខ:............អយកខ.

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្អាកដំណើរការបង្រៀន និងរៀន ជាបណ្តោះអាសន្ន ក្នុងស្រុកសំឡូត ស្រុកកំរៀង ស្រុកសំពៅលូន និងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

យោង៖ - សភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា ថៃ

- ការណែនាំរបស់រដ្ឋបាលខេត្តបាត់ដំបង
- អនុសាសន៍ណែនាំរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សូមជម្រាបជូនគណៈគ្រប់គ្រងគ្រប់គ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំអ្នកអាណាព្យាបាលនិងសិស្សានុសិស្សទាំងអស់ជ្រាបថា៖ដោយមានការឈ្លានពានពីសំណាក់យោធាថៃមកលើព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងភូមិសាស្ត្រស្រុកចំនួន៤(ស្រុកសំឡូត ស្រុកកំរៀង ស្រុកសំពៅលូន និងស្រុកភ្នំព្រឹក)ក្នុងខេត្តបាត់ដំបង ចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥នេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្តសម្រេចអនុញ្ញាតឱ្យគ្រឹះស្ថានសិក្សាទាំងអស់ក្នុងស្រុកទាំង៤ខាងលើផ្អាកដំណើរការបង្រៀន និងរៀនបណ្តោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី ដើម្បីធានាសុខសុវត្ថិភាពដល់ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ និងសិស្សានុសិស្សទាំងអស់បញ្ចៀសបាននូវគ្រោះថ្នាក់ដែលបណ្តាលមកពីការបាញ់ប្លោងកាំភ្លើងធំរបស់ភាគីថៃមកក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចបានគោរពជម្រាបជូនដំណឹងខាងលើសូមគណៈគ្រប់គ្រងគ្រប់គ្រឹះស្ថានសិក្សានៃស្រុកទាំង៤ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ អ្នកអាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ជ្រាបជាព័ត៌មាន និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ៥រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

បាត់ដំបង ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥

**ចម្លងជូន៖**

- ក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលខេត្តបាត់ដំបង
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-រដ្ឋបាលក្រុង\ស្រុក "ដើម្បីអនុវត្ត"
- ឯកសារ
- កាលប្បវត្ត គារ៉ី.រដ្ឋបាល

អាសយដ្ឋាន៖ ដំណាក់ហ្លួង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កម្ពុជា ទូរស័ព្ទ: 053 732 231
អ៊ីមែល: battambang@moeys.gov.kh គេហទំព័រ: www.moeys.gov.kh